

# អត្ថប្រយោជន៍អាហារ របស់អ្នកកំពុងផ្លាស់ប្ដូរ

## នេះជាអ្វីដែលអ្នកត្រូវដឹង

ចំណែកនៃអាហារសម្រាប់គ្រាអាសន្ននឹងបញ្ចប់ នៅខែកុម្ភៈ ហើយចំនួននៃអត្ថប្រយោជន៍អាហាររបស់អ្នកនឹងកាត់បន្ថយ នៅដើមខែមីនា ឆ្នាំ 2023។

ចាប់ពីខែមីនា ឆ្នាំ 2020 ដល់ខែកុម្ភៈ ឆ្នាំ 2023 រដ្ឋាភិបាលសហព័ន្ធបានចេញមូលនិធិសង្គ្រោះបន្ទាន់ បណ្ដោះអាសន្ន ដើម្បីផ្ដល់ជូនគ្រួសារនូវអត្ថប្រយោជន៍ អាហារបន្ថែមក្នុងអំឡុងពេលជំងឺរាតត្បាត COVID-19។

**ចាប់ពីខែមីនា ឆ្នាំ 2023 តទៅ**

ចំនួននៃអត្ថប្រយោជន៍អាហារដែលអ្នកនឹងទទួលបាន ដោយគ្មានអត្ថប្រយោជន៍សម្រាប់គ្រាអាសន្ននឹងអាស្រ័យ លើ កាលៈទេសៈជាក់លាក់របស់អ្នក។

Washington State Department of Social & Health Services
Transforming lives
DSHS 22-1899 (1/23)

## នេះជាអ្វី ដែលអ្នកអាចធ្វើបាន

**ស្វែងយល់ពីចំនួននៃអត្ថប្រយោជន៍ថ្មីរបស់អ្នក ថានឹងមានប៉ុន្មាន**

ហៅទូរសព្ទទៅលេខ 877-501-2233 ហើយជ្រើសរើស ជម្រើសសេវាកម្មស្វ័យប្រវត្តិ ឬចូលគណនីអត្ថប្រយោជន៍អតិថិជន របស់អ្នកនៅលើគេហទំព័រ WashingtonConnection.org។

**ស្វែងរកធនធានក្នុងស្រុក**

ចូលមើលគេហទំព័រ findhelp.org

ឬកម្មវិធីផ្គូផ្គង SNAP បង្កើនអត្ថប្រយោជន៍អាហាររបស់ អ្នក ដូច្នេះអ្នកអាចទិញផ្លែឈើ និងបន្លែកាន់តែច្រើន។

ឬ 211.org

**រាយការណ៍ពីការផ្លាស់ប្ដូរ**

ប្រសិនបើកាលៈទេសៈក្នុងជីវិតរបស់អ្នកបានប្រែប្រួល អ្នក អាចមានសិទ្ធិទទួលបានចំនួននៃអត្ថប្រយោជន៍កាន់តែច្រើន។ ហៅទូរសព្ទទៅលេខ 877-501-2233 ហើយចូលទៅកាន់ គេហទំព័រ WashingtonConnection.org ឬចូលទៅកាន់ Community Services Office (ការិយាល័យសេវា សហគមន៍) ក្នុងតំបន់មូលដ្ឋានរបស់អ្នក ដើម្បីរាយការណ៍ពី ការផ្លាស់ប្ដូរទំហំគ្រួសារ ប្រាក់ចំណូល ឬប្រាក់ចំណាយ។

## យើងយល់ថា វានឹងជះឥទ្ធិពល យ៉ាងខ្លាំងដល់ក្រុមគ្រួសារនៅ ទូទាំងទីក្រុង Washington ហើយយើងប្រចាំការនៅទីនេះ ដើម្បីជួយអ្នកក្នុងអំឡុងពេល ផ្លាស់ប្ដូរនេះ។

**ក្នុងករណីអ្នកមានចម្ងល់ណាមួយ**
សូមទាក់ទងមកយើងខ្ញុំតាមលេខ 877-501-2233។

# ទាក់ទងយើងខ្ញុំ

**ចំពោះព័ត៌មានបន្ថែម**

សូមចូលមើលយើងខ្ញុំតាមគេហទំព័រ dshs.wa.gov។

**ដាក់ពាក្យតាមអនឡាញ**

តាមគេហទំព័រ WashingtonConnection.org។

ហៅទូរសព្ទមកយើងខ្ញុំសម្រាប់ជម្រើសស្វ័យសេវាកម្ម 24 ម៉ោង/7 ថ្ងៃ ឬពិភាក្សាជាមួយអ្នកឯកទេសពីម៉ោង 8 ព្រឹកដល់ម៉ោង 5 ល្ងាចតាមរយៈលេខ 877-501-2233។

ជួបយើងខ្ញុំផ្ទាល់ដោយអញ្ជើញទៅកាន់ Community Services Office (ការិយាល័យសេវាសហគមន៍) ក្នុងតំបន់មូលដ្ឋានរបស់អ្នក។

ស្វែងរកការិយាល័យក្នុងតំបន់មូលដ្ឋានរបស់អ្នក៖ dshs.wa.gov/office-locations។



DSHS CSD
មជ្ឈមណ្ឌលសេវាកម្មអតិថិជន
PO BOX 11699
Tacoma, WA 98411-6699